ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ
តុលាការកំពូល

តុលាការកំពូល
សំណុំរឿងព្រហ្មទណ្ឌ
លេខ:១៥
ចុះថ្ងៃទី១៨-០២-២០០៥
សាលដីកាលេខ៖៤៨
ចុះថ្ងៃទី០៦-០៧-២០០៥

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ ២០០៥ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចតទៅ៖

១- ឯកឧត្តម ... ប្រធាន
២-លោក ... ចៅក្រម
៣- លោក ... ចៅក្រម
៤- លោក ... ចៅក្រម
៥- លោក ... ចៅក្រមរបាយការណ៍

ក្រឡាបញ្ជី
លោក...
តំណាងមហាអយ្យការ
លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសាទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ០១(ខ) ចុះថ្ងៃទី០៥ ខែមករាឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌ លេខ១៥ ចុះថ្ងៃទី១៨ ខែកុម្ភៈឆ្នាំ២០១៥ របស់តុលាការកំពូល។

***ពិបទ:*** ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅសង្កាត់បឹងកេងកង១ ខណ្ឌការមន ក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៣ និង ៩៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១-ជនជាប់ចោទឈ្មោះ **បសណ** (ម្ចាស់បណ្តឹងសាទុក្ខ) ភេទប្រុសអាយុ២៣ឆ្នាំ ជាតិខ្មែរ កើតនៅក្រុងភ្នំពេញ របររកស៊ីអតីតបុគ្គលិកក្រុមហ៊ុនសាមាគ្ស ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះលេខ៩១ ផ្លូវ២៨២ ក្រុមទី៧១ សង្កាត់បឹងកក់២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ... ម្តាយឈ្មោះ... នៅលីវ។ ក្នុងឃុំ។

មានមេធាវីលោក...

២-ជនជាប់ចោទឈ្មោះ **សសអ** ជាម្ចាស់បណ្តឹងសាទុក្ខ ភេទប្រុសអាយុ៣៦ឆ្នាំជាតិខ្មែរ កើតនៅខេត្តតាកែវ របររកស៊ីគ្រូបង្រៀនសាលាឯកជន ទីលំនៅមុនថ្ងៃចាប់ខ្លួនផ្ទះជួល សង្កាត់ទឹកល្អក់៣ ខណ្ឌទួលគោក ក្រុងភ្នំពេញ ឪពុកឈ្មោះ...ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០១នាក់។ ក្នុងឃុំ។

មានមេធាវីលោក...។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ជគន** ផ្ទេរសិទ្ធិឱ្យឈ្មោះ **ជម** (ជាចុងបណ្តឹងសាទុក្ខ) ភេទប្រុសអាយុ៣៧ឆ្នាំ ជាតិខ្មែរ របររកស៊ីប្រធានសហជីពកម្មករ ទីលំនៅសព្វថ្ងៃផ្ទះលេខ៩៤ ផ្លូវ៩៥ សង្កាត់បឹងកេងកង៣ ខណ្ឌចំការមន ក្រុងភ្នំពេញ។

មានមេធាវីអ្នកស្រី...។

-តាមពាក្យបណ្តឹង ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ឈ្មោះ **ជគន** បានប្តឹងពីជនល្មើស និងបក្សពួកដែលបានធ្វើឃាតលើរូបប្តីខ្លួនឈ្មោះ **ជវជ** ជា

ប្រធានសហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា ដោយហេតុថា នៅវេលាម៉ោង៩,៣០នាទីព្រឹក ប្ដីខ្លួនបានជិះម៉ូតូម៉ាកគុបជ្រុង៥០ពណ៌ទឹកប៊ិច មួយគ្រឿងឈប់នៅមុខតូបលក់កាសែតលេខ២ ជាប់របងវត្តលង្កា លើដងផ្លូវប៉ាស្ទ័រ ពេលកំពុងអានកាសែត ស្រាប់តែមានមនុស្ស០២នាក់ ស្លៀកពាក់ស៊ីវិល ជិះម៉ូតូមកបាញ់ប្ដីខ្លួនចំនួនបីគ្រាប់ មួយគ្រាប់ចំដើមទ្រូងខាងឆ្វេង មួយគ្រាប់ត្រូវចំកណ្ដាលក្បាល (គ្រាប់បៀម) និងមួយគ្រាប់ទៀតត្រូវកដៃឆ្វេង ដែលបណ្ដាលឱ្យដួលស្លាប់ភ្លាមនៅហ្នឹងកន្លែងកើតហេតុ។ ក្នុងរឿងនេះខ្លួនសុំឱ្យតុលាការរែកមុខរកឃាតករមកផ្ដន្ទាទោសតាមច្បាប់ និងសុំទាមទារសំណងជំងឺចិត្តជាប្រាក់ចំនួន៥០.000(ប្រាំម៉ឺនដុល្លាអាមេរិក)

-បានឃើញដីកាសម្រេចលេខ៧៩០៥ ត,ព្រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ ដែលបានសម្រេចៈ

១-ទទួលពាក្យសុំនៅក្រៅឃុំរបស់លោកមេធាវី...ចុះថ្ងៃទី១៨ខែតុលាឆ្នាំ២០០៤ របស់លោកមេធាវី...ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោល ដោយខុសនឹងគតិច្បាប់។

២-បន្តការឃុំខ្លួនលើជនជាប់ចោទឈ្មោះ **បសណ** និង **សសអ** តាមដីកាឃុំខ្លួនលេខ១៤៧ និង១៤៧ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៤ ជាបន្តទៀតតាមនីតិវិធី។

-បានឃើញបណ្ដឹងឧទ្ធរណ៍លេខ៥២(ឋ) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោកមេធាវី...ការពារជនជាប់ចោទឈ្មោះ **បសណ** និងបណ្ដឹងឧទ្ធរណ៍លេខ៥៣ ចុះថ្ងៃទី០៥ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោកមេធាវី ... ការពារជនជាប់ចោទឈ្មោះ **សសអ** ប្ដឹងមិនសុខចិត្តនឹងដីកាសម្រេចលេខ៧៩០៥

ត.ព្រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ របស់ចៅក្រមស៊ើបអង្កេតតុលាការក្រុងភ្នំពេញ លើដីកាសម្រេចទាំងមូល។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ០១"ខ" ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេច៖

១-ទទួលបណ្តឹងឧទ្ធរណ៍លេខ៥២(ឋ) ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោក...និងលេខ៥៣(ឋ) ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០០៤ របស់លោក...ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចលេខ៧៩០៥ ត.ព្រ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ របស់តុលាការក្រុងភ្នំពេញ ទុកជាបានការ។ សាលដីកានេះជំនុំជម្រះ ជាសាធារណៈនៅថ្ងៃទី០៤ ខែមករា ឆ្នាំ២០៥ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ ប្រកាសជាសាធារណៈនៅថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ កំបាំងមុខជនជាប់ចោទ មេធាវីការពារជនជាប់ចោទ និងតំណាងដើមបណ្តឹងរដ្ឋប្បវេណី តែទុកជាចំពោះមុខមានអានុភាពអនុវត្តទោះជាមានបណ្តឹងសាទុក្ខក៏ដោយ ។ បើកផ្លូវសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់លោកមេធាវី...ការពារជនជាប់ចោទឈ្មោះ **សសអ** និងបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់លោកមេធាវី...ការពារជនជាប់ចោទឈ្មោះ **បសណ** ប្តឹងមិនសុខចិត្តសាលដីកាព្រហ្មទណ្ឌលេខ០១(ខ) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញសារណា ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៥ របស់លោកមេធាវី ...ការពារឱ្យជនជាប់ចោទឈ្មោះ **បសណ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានឃើញសារណា ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៥ របស់លោកមេធាវី ...ការពារឱ្យជនជាប់ចោទឈ្មោះ **សសអ** (ជាម្ចាស់បណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានឃើញសារណាតប ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១៥ របស់ឈ្មោះ **ជមន** ជាតំណាងឱ្យជនរងគ្រោះឈ្មោះ **ជគន** (ជាចុងបណ្តឹងសាទុក្ខ) ធ្វើឡើងតាមកំណត់ច្បាប់។

-បានស្តាប់ចៅក្រមរបាយការណ៍ អានរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ ជនជាប់ចោទឈ្មោះ **បសណ, សសអ** ត្រូវចោទពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ប្រព្រឹត្តិនៅក្រុងភ្នំពេញ កាលពីថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ តាមមាត្រា៣ ច្បាប់ស្តីពីស្ថានទម្ងន់ទោស និងមាត្រា៥៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលសាលាឧទ្ធរណ៍សម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវហើយ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ **បសណ** (ម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ មូលហេតុដែលខ្ញុំប្តឹងសាទុក្ខមកពី៖

-តុលាការឃុំខ្លួនខ្ញុំហួសកំណត់ច្បាប់

-ខ្ញុំមិនបានដឹងរឿងរ៉ាវទាំងអស់នេះទេ ហើយក៏មិនដែលស្គាល់ឈ្មោះ **សសអ** ដែរ។

-ខ្ញុំបានឆ្លើយ សូមបដិសេធតាំងពីដំបូង តែប៉ូលីសគាបឱ្យខ្ញុំឆ្លើយនូវអ្វី តាមការបង្គាប់បញ្ជាឱ្យឆ្លើយ។ ខ្ញុំជាមនុស្សស្អាតស្អំគ្មានកំហុស គេយកខ្ញុំលាប ពណ៌ តុលាការក្រុងភ្នំពេញបានលើកលែងចោទប្រកាន់ខ្ញុំហើយៗ ត្រូវបាន សាលាឧទ្ធរណ៍បដិសេធចោលទៅវិញ។ ដូច្នេះ ទើបខ្ញុំប្តឹងសុំនៅក្រៅឃុំ ជាប ណ្តោះអាសន្ន ណាមួយខ្ញុំត្រូវបានគេទិញទឹកចិត្តទេ។

-តុលាការក្រុងភ្នំពេញ បានកោះឱ្យខ្ញុំចូលសវនាការ ប៉ុន្តែសវនាការនេះ ត្រូវបានលើកទៅវិញ ដោយមូលហេតុ មេធាវីរបស់ខ្ញុំមិនបានចូលរួម។ដូច្នេះការ ឃុំខ្លួនរបស់ខ្ញុំរហូតមកដល់ពេលនេះ គឺ១១ឆ្នាំជាង ខ្ញុំបាទសំណូមពរដល់ តុលាការ សុំនៅក្រៅឃុំជាបណ្តោះអាសន្នសិន រង់ចាំតុលាការសម្រេចដល់អង្គ សេចក្តីជាក្រោយ។

-បានស្តាប់ចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ **សសអ** (ជាម្ចាស់ប ណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា មូលហេតុដែលខ្ញុំប្តឹងសាទុក្ខមកពី៖

-ប៉ូលីសចាប់ខ្ញុំគ្មានដីកាពីតុលាការ ខ្ញុំមិនបានស្គាល់ឈ្មោះ **បសណ** ទេ ហើយប៉ូលីស សម្រេចដាក់គុកខ្ញុំតែម្តង។

-ការឃុំខ្លួនខ្ញុំមានរយៈពេលយូរ

-តុលាការក្រុងភ្នំពេញ បានលើកលែងចោទប្រកាន់ខ្ញុំ និងសម្រេចបើក សវនាការម្តងមកហើយ ប៉ុន្តែត្រូវ លើកទៅវិញមូលហេតុមេធាវីខ្ញុំមិនបានចូលរួ ម។

-តុលាការក្រុងភ្នំពេញគ្មានលទ្ធភាពរកយុត្តិធម៌ឱ្យខ្ញុំបាន ទើបខ្ញុំប្តឹងមក តុលាការកំពូលទៀត។ ដូច្នេះខ្ញុំ សំណូមពរដល់តុលាការកំពូល សូមឱ្យតុលាការ កំពូលឱ្យខ្ញុំបាទ នៅក្រៅឃុំជាបណ្តោះអាសន្នផង។

-បានស្តាប់ចម្លើយអះអាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ជមន** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ តាមចម្លើយជនជាប់ចោទ សាក្សី និងភស្តុតាងនៅប៉ូលីស មិនត្រឹមត្រូវទេ មេធាវី ជនជាប់ចោទសុំតុលាការឱ្យជនជាប់ចោទនៅក្រៅឃុំ ជាការត្រឹមត្រូវ ព្រោះជនជាប់ចោទពុំមែនជាអ្នកសម្លាប់បងខ្ញុំឡើយ តុលាការត្រូវរកឱ្យឃើញអ្នកនៅពីក្រោយខ្នង។ ខ្ញុំមានសាក្សីឃើញច្បាស់ពេលកើតហេតុ តែគេមិនបានមកឆ្លើយទេ ព្រោះមិនធានាសន្តិសុខឡើយ។ ដូច្នេះខ្ញុំសូមដកពាក្យបណ្តឹងរបស់ខ្ញុំមកវិញ។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **បសណ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ ក្រោយពីបានស្តាប់ថៅក្រមរបាយការណ៍ អានរបាយការណ៍ ឃើញថាកូនក្តីខ្ញុំជាប់ចោទពីបទប្រើប្រាស់អាវុធខុសច្បាប់ និងឃាតកម្មគិតទុកជាមុននេះ តុលាការមិនអនុញ្ញាតឱ្យកូនក្តីខ្ញុំនៅក្រៅឃុំជាបណ្តោះអាសន្នទេ ឃើញថាមិនត្រឹមត្រូវទេព្រោះថា៖

១-ពុំមានច្បាប់ចែង

២-កូនក្តីខ្ញុំស្ថិតក្នុងដំណាក់កាលស៊ើបអង្កេត ការឃុំខ្លួនលើសកំណត់ច្បាប់ត្រូវបានដោះលែង យោងតាមមាត្រា៨ រដ្ឋធម្មនុញ្ញច្បាប់ស្តីពីសន្ធិសញ្ញា មាត្រា១៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាល មាត្រា៣៨ រដ្ឋធម្មនុញ្ញ មាត្រា៦៥ ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ និងមាត្រា២២ ច្បាប់ព្រហ្មទណ្ឌអន្តរកាល អ្នកឃុំខ្លួនលើសក៏ត្រូវមានទោសដែរ។ ម្យ៉ាងទៀតតុលាការក្រុងភ្នំពេញ បានលើកលែងចោទប្រកាន់កូនក្តីខ្ញុំ ម្តងមកហើយ ដូច្នេះរាល់សេចក្តីសម្រេច ដែលចេញដោយតុលាការ គឺចាត់ទុកថា តុលាការបានបើកសវនាការ មេត្តាឱ្យកូនក្តីខ្ញុំនៅក្រៅឃុំជាបណ្តោះអាសន្នផង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក... មេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **សសអ** (ជាម្ចាស់បណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ យុត្តិសាស្ត្ររបស់តុលាការកំពូលសម្រេចមិនឱ្យកូនក្តីខ្ញុំ នៅក្រៅឃុំបណ្តោះអាសន្ន ក្នុងបទឧក្រិដ្ឋ ខ្ញុំឆ្ងល់ថា៖

១-យុត្តិសាស្ត្រនេះផ្ទុយពីច្បាប់ ដែលច្បាប់ពុំមានចែង។

២-ជាការសម្រេចរំលោភច្បាប់ ថ្ងៃលើកលែងចោទប្រកាន់នេះ ពុំមែនជាថ្ងៃសំរាប់ ថ្ងៃសវនាការទេ ខ្ញុំគិតថា រយៈពេលនៃការឃុំខ្លួន គឺគិតពីថ្ងៃក្នុងដីកាឃុំខ្លួនចាស់ ហើយការឃុំខ្លួននេះ វាលើសពីនីតិវិធីហើយ។ ដូច្នេះសូមតុលាការ មេត្តាឱ្យកូនក្តីខ្ញុំនៅក្រៅឃុំជាបណ្តោះអាសន្នផង។

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់អ្នកស្រី...មេធាវីការពារឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ **ជមន** (ជាចុងបណ្តឹងសាទុក្ខ) នៅពេលជំនុំជម្រះថា៖ ការសម្រេចរបស់កូនក្តីនាងខ្ញុំនេះ គឺជួយសម្រួលដល់តុលាការឱ្យជនជាប់ចោទនៅក្រៅឃុំ សូមតុលាការមេត្តាពិចារណាអំពីករណីនេះផង។

-បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម របស់តំណាងមហាអយ្យការអមតុលាការកំពូលនៅពេលជំនុំជម្រះថា៖ ការឃុំខ្លួនក្នុងបទឧក្រិដ្ឋនេះ ជាយុត្តិសាស្ត្ររបស់តុលាការកំពូល ដូច្នេះសូមតុលាការឃុំខ្លួនជនជាប់ចោទបន្តទៀត។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទឈ្មោះ**បសណ**, ឈ្មោះ **សសអ** ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីជនជាប់ចោទ និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## តុលាការកំពូល

-យល់ឃើញថា បណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៩របស់លោកមេធាវី...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **សសអ** និងបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៩ របស់លោកមេធាវី...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **បសណ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជម្រះបានដោយយោងតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី

-យល់ឃើញថា ការដែលជនជាប់ចោទឈ្មោះ **បសណ** និង ឈ្មោះ **សសអ** ព្រមទាំងមេធាវីរបស់ជនជាប់ចោទលើកឡើងថានៅពេលសវនាការនេះថា សុំឱ្យតុលាការកំពូល សម្រេចឱ្យជនជាប់ចោទនៅក្រៅឃុំបណ្តោះអាសន្នសិន ពីព្រោះថា ជនជាប់ចោទបានត្រូវឃុំខ្លួនបណ្តោះអាសន្នលើសពី៦ខែដោយមិនទាន់បានជំនុំជម្រះ ដែលតាមមាត្រា១៤ និង២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ត្រូវដោះលែងជនជាប់ចោទនោះ ជាការភាន់ច្រឡំពីព្រោះថា៖

ក/-តាមមាត្រា២១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលបញ្ជាក់ថា៖ ជនជាប់ចោទត្រូវបានកាត់ក្តីយ៉ាងយូរបំផុត៦ខែ ក្រោយពេលចាប់ខ្លួន។ តុលាការក្រុងភ្នំពេញ បានចេញដីកាសម្រេចលើកលែងចោទប្រកាន់ និងបង្គាប់ឱ្យដោះលែងជនជាប់ចោទ តែក្នុងរយៈពេលជាង០១ខែប៉ុណ្ណោះក្រោយចាប់ខ្លួន។ ប៉ុន្តែការមិនអាចដោះលែងបាន ដោយសារជាប់បណ្តឹងឧទ្ធរណ៍របស់តំណាងអយ្យការតាមមាត្រា៨ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងមាត្រា១៦១ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ហើយដែលតាមមាត្រា៩០ថ្មីនៃច្បាប់វិសោធនកម្មនីតិវិធីព្រហ្មទណ្ឌ ការដោះលែងត្រូវតែផ្អាកសិន។ ដូច្នេះពុំ

មានការឃុំខ្លួនខុសច្បាប់ លើជនជាប់ចោទទាំង២នាក់ទេ ដែលតម្រូវឱ្យដោះលែងតាមមាត្រា២២នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលទេ។

ខ/-ការកាត់ក្តីដែលត្រូវអនុវត្តមិនឱ្យលើសពី៦ខែ ក្រោយការចាប់ខ្លួននោះមិនមែនមានន័យថា ជាការកាត់ក្តីឱ្យស្ពាពរទេ ពីព្រោះច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី និងច្បាប់នីតិវិធីព្រហ្មទណ្ឌបានបើកឱ្យមានការប្តឹងទាស់ ប្តឹងឧទ្ធរណ៍ និងប្តឹងសាទុក្ខ ហើយបណ្តឹងទាំងនេះសុទ្ធតែមានអានុភាពផ្អាកការអនុវត្ត។

-យល់ឃើញថា នៅពេលសវនាការនេះ ជនជាប់ចោទទាំង២នាក់សុទ្ធតែលើកសំណូមពរឱ្យតុលាការកំពូល ដោះលែងខ្លួនឱ្យនៅក្រៅឃុំ ពីព្រោះខ្លួនជាមនុស្សស្អាតស្អំគ្មានកំហុស ត្រូវបានគេប្រឌិតភស្តុតាងលាបពណ៌ឱ្យខ្លួននោះជាការពុំត្រឹមត្រូវទេ ពីព្រោះថារហូតដល់ពេលនេះ ជនជាប់ចោទពុំទាន់មានភស្តុតាងបន្ទុកគ្រប់គ្រាន់ទេ ដោយហេតុថា ចម្លើយសាក្សីនៅកន្លែងកើតហេតុឆ្លើយបញ្ជាក់ពីភិនភាគឃាតករ គឺដូចគ្នានឹងភិនភាគជនជាប់ចោទ សាក្សីនៅផ្ទះសំណាក់នីនី គេស្គាល់ច្បាស់ថា ឈ្មោះ **បសណ** យប់ថ្ងៃទី២១ ព្រឹកថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ពិតជាបានទៅដេកផ្ទះសំណាក់គេ ដែរនៅភ្នំពេញ (ពុំមែននៅអ្នកលឿងដូចសាក្សីជនជាប់ចោទបំភ្លឺទេ) សាក្សីជនជាប់ចោទសុទ្ធតែបញ្ជាក់ថាជនជាប់ចោទទាំង២នាក់ ធ្លាប់ដើរស៊ីផឹកជក់គ្រឿងញៀនជាមួយគ្នា (ពុំមែនមិនស្គាល់គ្នាទេ) ។ សំបកគ្រាប់ ក្បាលគ្រាប់ និង អាវុធK៥9 ជាវត្ថុតាងដែលរឹបអូសបាន ព្រមទាំងលទ្ធផលកោសល្យវិច្ច័យផ្ទៀងផ្ទាត់ សំបកគ្រាប់ដែលដកហូតពីកន្លែងកើតហេតុ និងក្បាលគ្រាប់ដែលយកចេញពីសាកសពជាមួយនឹងអាវុធK៥9 ដែលជនជាប់ចោទ បាននាំនគរបាលទៅយកនៅកន្លែង ដែលខ្លួនទម្លាក់ចោលបញ្ជាក់ថា សំបកគ្រាប់ និងក្បាលគ្រាប់ ពិតជាបាញ់ចេញពីកាំភ្លើងK59

ដែលរឹបអូសបានមែន។ ភស្តុតាងទាំងនេះ សុទ្ធតែមានភាពស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយជនជាប់ចោទឈ្មោះ **បសណ** នៅមុខនគរបាល នៅមុខតំណាងអយ្យការ នៅមុខចៅក្រមស៊ើបអង្កេតទាំងអស់ ដែលដាក់បន្ទុកទៅលើជនជាប់ចោទទាំង២នាក់នេះ។ ដូច្នេះការដែលឈ្មោះ **បសណ** ឆ្លើយបដិសេធចម្លើយសារភាពរបស់ខ្លួននៅនគរបាលនៅអយ្យការ និងនៅចៅក្រមស៊ើបអង្កេត តែមួយមុខគត់ ពុំអាចដោះបន្ទុកឱ្យជនជាប់ចោទទេ។ម្យ៉ាងទៀតចម្លើយដោះសារបស់ជនជាប់ចោទឈ្មោះ**បសណ** ថាខ្លួនឆ្លើយសារភាព ដោយមានការលួងលោមទិញទឹកចិត្តនិងគំរាមកំហែងពីនគរបាលនោះពុំមានភស្តុតាងអ្វីទាំងអស់។

-យល់ឃើញថា ជនជាប់ចោទទាំង២នាក់ត្រូវចោទពីបទឧក្រិដ្ឋ ដោយសុទ្ធតែជាជនដែលគ្មានទីលំនៅច្បាស់លាស់ គ្មានការងារធ្វើ សេពគ្រឿងញៀន ឈ្មោះ **បសណ** ត្រូវឳពុកម្ដាយកាត់កាលចោលទៀត ដែលបញ្ជាក់ថា បើឱ្យនៅក្រៅឃុំ ពិតជារត់គេចខ្លួន គ្មានអ្វីអាចធានាបានថា ជនជាប់ចោទប្រាកដជាមកបង្ហាញខ្លួនចំពោះមុខតុលាការវិញទេ។ ដូច្នេះតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ជនជាប់ចោទពុំត្រូវបានអនុញ្ញាតឱ្យនៅក្រៅឃុំបណ្ដោះអាសន្នទេ។ ម្យ៉ាងទៀតសាលាឧទ្ធរណ៍ បានចាត់ការដល់ដំណាក់កាលបដិសេធ ការលើកលែងចោទប្រកាន់ទៅហើយ។

-យល់ឃើញថាការដែលមេធាវីជនជាប់ចោទលើកឡើងនៅពេលសវនាការនេះថា យុត្តិសាស្ត្ររបស់តុលាការកំពូល ដែលសម្រេចមិនឱ្យជនជាប់ចោទក្នុងបទឧក្រិដ្ឋ នៅក្រៅឃុំបណ្ដោះអាសន្នជាការខុសច្បាប់នោះ គឺជាការភាន់ច្រឡំ ពីព្រោះពុំដែលមានយុត្តិសាស្ត្រណាមួយរបស់តុលាការកំពូលដែលផ្ទុយនឹងច្បាប់ទេ។ យុត្តិសាស្ត្ររបស់តុលាការកំពូលក្នុងការឃុំខ្លួនតាមមាត្រា១៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលរយៈពេល៦ខែ ចំពោះបទល្មើសមជ្ឈិម ដែលមាន

លក្ខខ័ណ្ឌគ្រប់គ្រាន់អាចឱ្យនៅក្រៅឃុំបាន ប៉ុន្តែចំពោះបទឧក្រិដ្ឋតុលាការកំពូលកំណត់ថា បើឱ្យនៅក្រៅឃុំជនជាប់ចោទប្រាកដជារត់គេចខ្លួន ហើយគ្មានឧក្រិដ្ឋជនណាសុខចិត្តត្រឡប់មកទទួលទោសឧក្រិដ្ឋមុខតុលាការវិញទេ។ដូច្នេះយុត្តិសាស្ត្ររបស់តុលាការកំពូលដែលកំណត់ថា ក្នុងបទឧក្រិដ្ឋជន ដែលត្រូវឃុំខ្លួនបណ្តោះអាសន្នក្នុងរយៈពេល៦ខែ មិនអនុញ្ញាតឱ្យនៅក្រៅឃុំគ្មានអ្វីផ្ទុយពីច្បាប់ទេ។

-យល់ឃើញថា ថ្វីបើដើមបណ្តឹងរដ្ឋប្បវេណីបានសុំឱ្យជនជាប់ចោទបាននៅក្រៅឃុំ ដោយមិនប្តឹងពីជនជាប់ចោទ ទាំងពីរនាក់នេះមែន ប៉ុនតុលាការកំពូលមិនពិចារណាទេ ពីព្រោះដើមបណ្តឹងរដ្ឋប្បវេណី ពុំមែនជាម្ចាស់បណ្តឹងអាជ្ញា ដូចមានចែងក្នុងមាត្រា៤ និងមាត្រា៨១ នៃច្បាប់នីតិវិធីព្រហ្មទណ្ឌទេ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ(ខ) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០១៥ របស់សាលាឧទ្ធរណ៍ ដែលសម្រេចមកនេះមានលក្ខណៈត្រឹមត្រូវតាមទម្រង់ នឹងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី

១-ទទួលបណ្តឹងសាទុក្ខលេខ១២ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់លោកមេធាវី...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **សសអ** និងបណ្តឹងសាទុក្ខលេខ១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ របស់លោកមេធាវី...ជាមេធាវីការពារឱ្យជនជាប់ចោទឈ្មោះ **បសណ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ១១(ខ) ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៥ ចុះថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០០៥ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីបញ្ចូលក្នុងរឿងអង្គសេចក្តី។

៤-សាលដីកានេះជំនុំជម្រះនៅថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៥ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៥។